ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ធ្វើឱ្យមានការផ្លាស់ប្តូរមួយ
# គួរឱ្យកត់សំគាល់ និងយូរអង្វែង

## ផែនការសកម្មភាពជាតិសំរាប់កុមារកំព្រា
## កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍ និង
## កុមារងាយរងគ្រោះដទៃទៀត ក្នុងប្រទេសកម្ពុជា
## ២០០៨ - ២០១០




មិថុនា ឆ្នាំ២០០៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ធ្វើឱ្យមានការផ្លាស់ប្តូរមួយ
# គួរឱ្យកត់សំគាល់ និង យូរអង្វែង

## ផែនការសកម្មភាពជាតិសំរាប់កុមារកំព្រា
## កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍ និង
## កុមារងាយរងគ្រោះដទៃទៀត ក្នុងប្រទេសកម្ពុជា
## ២០០៨ — ២០១០

ខែមិនា ឆ្នាំ២០០៨

# មាតិកា

**អារម្ភកថារបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា**....................................២

សេចក្តីថ្លែងអំណរគុណ..........................................................................................................៣

អក្សរកាត់........................................................................................................................៤

**សេចក្តីផ្តើម**.................................................................................................................................៥

សាវតារបស់ប្រទេសកម្ពុជា.....................................................................................................៥

សេចក្តីសង្ខេប នៃការប៉ាន់ប្រមាណស្ថានភាពកុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយមេរោគ អេដស៍ និង ជំងឺអេដស៍ និងកុមារងាយរងគ្រោះដទៃទៀត ...........................................................៨

**ផែនការសកម្មភាពជាតិ**....................................................................................................................១៤

ការបង្កើតឡើងនូវផែនការសកម្មភាពជាតិ.....................................................................................១៤

គោលការណ៍ណែនាំ.............................................................................................................១៥

ទស្សនទាន :...................................................................................................................១៧

គោលដៅ :......................................................................................................................១៨

ភ្ជាប់បណ្តាញជាមួយផែនការ យុទ្ធសាស្ត្រ និង ទិសដៅជាតិដទៃផ្សេងទៀត.............................១៨

គោលបំនងរបស់ផែនការសកម្មភាពជាតិ.......................................................................................២០

យុទ្ធសាស្ត្រគន្លឹះទាំង ៥ .......................................................................................................២២

**បទដ្ឋានកញ្ចប់អប្បបរិមានៃកិច្ចគាំទ្រ**..........................................................................................២២

**ឧបសម្ព័ន្ធទី១**..................................................................................................................................២៦

**ឯកសារយោង**.............................................................................................................................៣២

សូម ពិនិត្យមើលទំព័រឡើងវិញ

# សេចក្តីថ្លែងអំណរគុណ

ក្រុមការងារថ្នាក់ជាតិតាមដានស្ថានភាពកុមារកំព្រា និងកុមារងាយរងគ្រោះ ដែលដឹកនាំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នកទាំងអស់គ្នាដែលបានរួមចំណែកក្នុងការអភិវឌ្ឍន៍នូវផែនការសកម្មភាពជាតិសំរាប់កុមារកំព្រា កុមារទទួលផលប៉ះពាល់ ដោយមេរោគអេដស៍ និងកុមារងាយរងគ្រោះដទៃទៀត សំរាប់ ឆ្នាំ ២០០៨- ២០១០ នេះ ។

សូមថ្លែងអំណរគុណជាពិសេសដល់សមាជិកទាំងអស់នៃគណៈកម្មការដឹកនាំ ចំពោះកិច្ចខិតខំប្រឹងប្រែង និងការណែនាំបច្ចេកទេសក្នុងដំណើរការនេះ និងសូមអរគុណដល់ UNICEF, DFID, Save the Children Australia និង Family Health International ចំពោះការជួយគាំទ្រជាហិរញ្ញវត្ថុ ។

យើងខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះ លោកស្រី Jenne Roberts, លោកស្រី Serey Phal និង ទីប្រឹក្សាជាច្រើននាក់ទៀតដែលបានជួយសម្របសម្រួលក្នុងការអភិវឌ្ឍន៍ផែនការនេះ និងបានសរសេរ សមាសភាគជាច្រើនរបស់វា ។ យើងខ្ញុំក៏ទទួលស្គាល់ផងដែរនូវមតិយោបល់និងទិន្នន័យ ជាច្រើនដ៏មានតំលៃដែលបានផ្តល់ដោយក្រុមហ៊ុន Constella Futures ។

លើសពីនេះទៅទៀត យើងខ្ញុំសូមសម្តែងនូវការដឹងគុណដល់ អង្គការមិនមែនរដ្ឋាភិបាល អង្គការសាសនា និង ទីភ្នាក់ងាររដ្ឋាភិបាលជាច្រើនទៀត ដែលបានចូលរួមសិក្ខាសាលាថ្នាក់ខេត្ត និងជាតិ ដើម្បីធ្វើអោយផែនការសកម្មភាពនេះកាន់តែបានប្រសើរឡើងនិងមានសុពលភាព ។

ជាចុងក្រោយនេះ យើងខ្ញុំសូមអរគុណដល់កុមារទាំងអស់ដែលបានរួមចំណែកផ្តល់នូវគំនិត និង ទិន្នន័យរបស់ពួកគេ និងដែលបានចែករំលែកនូវមតិយោបល់ និងបទពិសោធន៍ ដែលជួយឱ្យយើងខ្ញុំធានាបានថាផែនការនេះអាចដោះស្រាយរាល់តំរូវការរបស់ពួកគេ ។

## អក្សរកាត់

| | |
|---|---|
| CMDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា |
| CRC | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| DFID | នាយកដ្ឋានចក្រភពអង់គ្លេសសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ |
| FHI | អង្គការសុខភាពគ្រួសារអន្តរជាតិ |
| HIV | មេរោគអេដស៍: វីរុសដែលបំផ្លាញប្រព័ន្ធភាពស៊ាំការពាររាងកាយរបស់មនុស្ស |
| MoSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| NAA | អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ |
| NCHADS | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NOVCTF | ក្រុមការងារថ្នាក់ជាតិពហុផ្នែក ស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ |
| OVC | កុមារកំព្រា និងកុមារងាយរងគ្រោះ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| UNAIDS | កម្មវិធីអង្គការសហប្រជាជាតិរួមគ្នាប្រយុទ្ធ នឹងជំងឺអេដស៍ |
| UNICEF | មូលនិធិសហប្រជាជាតិសំរាប់កុមារ |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍន៍អន្តរជាតិ |

# សេចក្តីផ្តើម

## សាវតារ

កុមារ និង យុវជនអាយុ១៨ឆ្នាំចុះ មានចំនួនស្មើរពាក់កណ្តាលនៃចំនួនប្រជាជនសរុបក្នុងប្រទេសកម្ពុជា ដែលមានចំនួន ១៣,៨លាននាក់។ សមាមាត្រដ៏ច្រើនលើសលប់ (៨៥%) នៃចំនួនប្រជាជនសរុប រស់នៅតាមទីជនបទ និង ប្រកបមុខរបរចិញ្ចឹមជីវិតដោយពឹងផ្អែកលើវិស័យកសិកម្ម។ កម្ពុជាកំពុងទទួលបាននូវស្ថេរភាពគួរឱ្យកត់សំគាល់មួយ បន្ទាប់ពីប្រទេសនេះបានទទួលរងនូវការបំផ្លិចបំផ្លាញ ផ្នែកសេដ្ឋកិច្ច និង សង្គម ពីសង្គ្រាមស៊ីវិល និងរបបប្រល័យពូជសាសន៍ អស់រយៈពេលជាងបីទសវត្សកន្លងមក។ ពិនិត្យ លើទិដ្ឋភាពទូទៅ ជាង៣០%នៃចំនួនប្រជាជនសរុប មិនទាន់បានឆ្លងផុតពីភាពក្រីក្រ ។

ភាពងាយរងគ្រោះនៅមានច្រើន[1] ។ ប្រជាជនភាគច្រើនមានការពឹងផ្អែកទៅលើវិស័យកសិកម្មដើម្បីចិញ្ចឹមជីវិតហើយផលដំណាំស្រូវអាស្រ័យទៅលើស្ថានភាព អាកាសធាតុមិនទៀងទាត់ ។

[1] កថាខ័ណ្ឌខាងក្រោមស្តីអំពីភាពងាយរងគ្រោះត្រូវយកស្រង់ពី ការគ្រប់គ្រងការគ្រោះថ្នាក់ និងភាពងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជា ការប៉ាន់ប្រមាណ និងយុទ្ធសាស្ត្រសំរាប់ការពារសង្គម (ធានាគារពិភពលោកខែមិថុនា ឆ្នាំ២០០៦)

ចំពោះជនក្រីក្រដែលរស់នៅក្នុងទីក្រុង និងជាពិសេសជនទេសន្តរប្រវេសន៍ ការខ្វះខាតជំរកដែលមានសុវត្ថិភាពធ្វើឱ្យជនក្រីក្រភាគច្រើនស្ថិតក្នុងស្ថានភាពមិនទៀងទាត់ដោយរស់នៅឥតច្បាប់លើដីរបស់អ្នកដទៃធ្វើឱ្យគេប្រឈមមុខទៅនឹងគ្រោះថ្នាក់ខ្ពស់នៃការបណ្តេញចេញភ្លាមៗ។ ការរផ្លាស់ប្តូរទីលំនៅពីជនបទមកកាន់ទីក្រុងក៏បង្កើនថែមទៀតនូវភាពងាយរងគ្រោះដល់កុមារផងដែរ មិនថានៅក្នុងស្ថានភាពដែលឪពុកម្តាយទុកកុមារនៅក្នុងភូមិ ឬក៏ពេលកុមារតាម ឪពុកម្តាយទៅកន្លែងទីក្រុងដែលមិនមានសុវត្ថិភាពនោះទេ។

កម្ពុជាកំពុងជួបប្រទះការឆ្លងរាលដាលនៃមេរោគអេដស៍ ដែលនោះគឺជាចំនួនបូកសរុបនៃការឆ្លងរាលដាលតូចៗជាច្រើន និងបែងចែកតាមប្រភេទនៃកំរិតឆ្លងខ្ពស់ ក្នុងចំនោមអ្នកបំរើសេវាផ្លូវភេទ អតិថិជនរបស់ពួកគេ ក្រុមបុរសស្រលាញ់បុរស និង ក្រុមអ្នកប្រើប្រាស់គ្រឿងញៀនដោយការចាក់បញ្ចូល មួយចំនួនតូចដែលកំពុងតែរីករាលដាលធំឡើងៗ។ កិច្ចខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់ មានភាពជោគជ័យគួរឱ្យកត់សំគាល់ ដោយទិន្នន័យតាមដានសង់ទីណែលមេរោគអេដស៍ បានបង្ហាញឱ្យឃើញនូវការថយចុះក្នុងកំរិតថេរមួយនៃអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ក្នុងចំណោមប្រជាជនទូទៅ ពីកំរិត៣% ដែលជាតួលេខមួយខ្ពស់នៅក្នុង ឆ្នាំ១៩៩៧ មកត្រឹម 0,៩%នាពេលបច្ចុប្បន្ន ក្នុងក្រុមអាយុពី ១៥-៤៩ឆ្នាំ។ ប្រេវ៉ាឡង់មេរោគអេដស៍ ក្នុងចំនោមស្ត្រីដែលបានមកទទួលការពិនិត្យផ្ទៃពោះមុនពេលសំរាល កំពុងតែមានការថយចុះ ហើយត្រូវបានប៉ាន់ប្រមាណក្នុងកំរិតជាតិថាមានអត្រា១,១%នៅក្នុងឆ្នាំ២00៦ បើទោះបីជាកំរិតអត្រានេះ មិនបានបង្ហាញការប្រែប្រួលនៃអត្រាទិន្នន័យនៅក្នុងតំបន់ទីក្រុងដែលតែងតែកើតមានឡើង និងមានកំរិតខ្ពស់ជាងក៏ដោយ[2] ។

គេប៉ាន់ប្រមាណក្នុងឆ្នាំ២00៦ ថាមានមនុស្សពេញវ័យប្រមាណ ៦៥.000នាក់ និង កុមារ ៦.000នាក់ កំពុងផ្ទុកមេរោគអេដស៍ និង ជាអ្នកជំងឺអេដស៍ ក្នុងប្រទេសកម្ពុជា[3] ។ ពុំមានការប្រមូលទិន្នន័យអ្នកឆ្លងមេរោគអេដស៍ថ្មីៗណាមួយត្រូវបានធ្វើឡើងឡើយ ប៉ុន្តែបើទោះជាយ៉ាងដូច្នេះក្តី នេះគឺជាការប៉ាន់ប្រមាណចុងក្រោយបំផុត ដែលបានឱ្យដឹងថា ចាប់ពីឆ្នាំ២00៣ ក្នុងមួយឆ្នាំៗមានមនុស្សចំនួន ៨.000នាក់ទៀតបានឆ្លងមេរោគអេដស៍ (ប្រហែល0,0៦% នៃចំនួនប្រជាជនសរុប) ដែលពាក់ កណ្តាលនៃ ចំនួននេះ គឺជាស្ត្រីដែលបានរៀបការរួច និង ១/៣ ទៀត ជាកុមារ[4] ។

ការឆ្លងរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ ភាពក្រីក្រ និង អសន្តិសុខស្បៀង បច្ចុប្បន្ននេះកំពុងគំរាមកំហែងការរស់នៅរបស់កុមារជាច្រើនក្នុងប្រទេសកម្ពុជា ជាពិសេសកុមារកំព្រា។ ការកាត់បន្ថយផលប៉ះពាល់នៃមេរោគអេដស៍ និង ភាពក្រីក្រ ចំពោះកុមារ និង គ្រួសាររបស់ពួកគេ ទាមទារឱ្យមានកិច្ចអន្តរាគមន៍ ដែលបំរើឱ្យសេចក្តីត្រូវការរបស់កុមារងាយរងគ្រោះគ្រប់រូបនៅក្នុងសហគមន៍។ វាក៏ទាមទារផងដែរនូវអន្តរាគមន៍ទាំងឡាយណា ដែលដោះស្រាយនូវសេចក្តីត្រូវការបន្ថែមទៀតរបស់កុមារដែលទទួលផលប៉ះពាល់ដោយផ្ទាល់ពីមេរោគអេដស៍ និង ជំងឺអេដស៍ ។

[2] សិក្ខាសាលាស្តីអំពីកិច្ចព្រមព្រៀងជារួមលើលទ្ធផលអង្កេតតាមដានសង់ទីណែលមេរោគអេដស៍ ក្នុងការប៉ាន់ប្រមាណមេរោគអេដស៍ក្នុងឆ្នាំ២00៦ សំរាប់កិច្ចប្រជុំផ្សព្វផ្សាយនៅក្នុងប្រទេសកម្ពុជា (ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២00៧) នៅសណ្ឋាគារសាន់វ៉េ ភ្នំពេញ ។

[3] Op cit

[4] មជ្ឈមណ្ឌលជាតិប្រយុទ្ធនិងជំងឺអេដស៍ សើរស្បែក និងកាមរោគ(២00៣) របាយការណ៍តាមដានសង់ទីណែលមេរោគអេដស៍ កម្ពុជា ។

ភាពកំព្រាឯកោឬងាយរងគ្រោះរបស់កុមារ ពុំមែនជាបាតុភូតដែលថ្មីនៅក្នុងប្រទេសកម្ពុជាឡើយ ហើយការឆ្លើយតប របស់គ្រួសារ និង សហគមន៍ ចំពោះកុមារកំព្រា រឺ កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍និងជំងឺអេដស៍តែងប្រកបដោយក្តីអាណិតអាសូរ។ បន្ទុកដ៏ធ្ងន់ធ្ងរក្នុងការថែទាំសមាជិកគ្រួសារដែលមានជម្ងឺអេដស៍ត្រូវធ្លាក់ទៅលើកុមារ រឺ បណ្តាលឱ្យប៉ះពាល់ដល់ការទទួលបាននូវកិច្ចការពារ ថែទាំ និង គាំទ្ររបស់កុមារ។

ហេតុដូច្នេះ ផែនការនេះផ្តោតទៅលើកុមារកំព្រាដោយសារគ្រប់មូលហេតុទាំងអស់ និង កុមារដែលទទួលផលប៉ះពាល់ដោយមេរោគអេដស៍ និង ជំងឺអេដស៍ផងដែរ។

## សេចក្តីសង្ខេប នៃការប៉ាន់ប្រមាណស្ថានភាពកុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយ មេរោគអេដស៍ និងកុមារងាយរងគ្រោះដទៃទៀត

*ការកំណត់ចំនួនកុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍ និងកុមារងាយរងគ្រោះដទៃទៀត និងតួលេខសំខាន់ៗខ្លះ:*

មានការប្រែប្រួលបន្តិចបន្តួចនៅក្នុងសមាមាត្ររួមនៃចំនួនកុមារដែលមានអាយុចាប់ពី 0 ដល់ ១៤ឆ្នាំ រវាងឆ្នាំ ២000 និង ២00៥។ ដោយប្រើប្រាស់តួលេខចំនួនប្រជាជននៅឆ្នាំ ២00៤ គេប៉ាន់ស្មានថានៅឆ្នាំ២00៥ មានកុមារកំព្រា ជាច្រើននាក់កំពុងរស់នៅក្នុងផ្ទះ បន្ថែមលើ កុមារកំព្រាប្រមាណ ៦ ១២១នាក់ដែល កំពុងរស់នៅក្នុង មជ្ឈមណ្ឌលកុមារកំព្រា។ ភាគច្រើននៃកុមារ កំព្រាទាំងអស់នេះបានបាត់បង់ឪពុក។ មានការល្បៀងគ្នាយ៉ាងខ្លាំងនៃ ចំនួនប្រេវ៉ាឡង់ កុមារកំព្រាពីខេត្តមួយទៅខេត្តមួយទៀត។ នៅក្នុងឆ្នាំ ២00៥ ខេត្តដែលមានចំនួនសមាមាត្រនៃកុមារកំព្រាខ្ពស់ជាងគេ រួមមាន: ខេត្តបាត់ដំបង/ប៉ៃលិន (១0%) ខេត្តឧត្តរមានជ័យ (៩%) និងខេត្តសៀមរាប (៩%)។ ទោះបីជាចំនួនប្រេវ៉ាឡង់នៃ កុមារ កំព្រានៅតំបន់ទីក្រុង និងជនបទមានភាពស្រដៀងគ្នាក៏ដោយ ក៏តំបន់ជនបទទទួលបន្ទុកនៃការថែទាំ កុមារកំព្រាច្រើនជាងនៅតាមតំបន់ទីក្រុង ពីព្រោះមានកុមារ រស់នៅទីនោះច្រើនជាង។

សិក្ខាសាលាដើម្បីបង្កើតការព្រមព្រៀងគ្នាថ្នាក់ជាតិ នៅឆ្នាំ ២00៧ ស្តីអំពីការប៉ាន់ស្មានមេរោគអេដស៍នៅប្រទេសកម្ពុជា បានធ្វើការប៉ាន់ស្មានថា មានកុមារកំពុងរស់នៅដោយផ្ទុកមេរោគអេដស៍ប្រមាណជា ៣ ៨00នាក់។ ដោយហេតុថា ចំនួន១.១ភាគរយនៃស្ត្រីមានផ្ទៃពោះមានផ្ទុកមេរោគអេដស៍ និងប្រសិនបើពុំមានអន្តរាគមន៍ដើម្បីការពារការឆ្លងពីម្តាយទៅទារកទេនោះ គេប៉ាន់ប្រមាណថានឹងមានទារកចំនួន

១,៥៤៧នាក់ កើតមកផ្ទុកមេរោគអេដស៍ជារៀងរាល់ឆ្នាំ។ នៅពេលបច្ចុប្បន្ននេះ ពុំទាន់មានការប៉ាន់ប្រមាណពីចំនួនកុមារដែលទទួលផលប៉ះពាល់ដោយមេរោគអេដស៍នៅឡើយទេ។

មរណៈភាពរបស់ឪពុកឬម្តាយធ្វើឱ្យមានបញ្ហាប្រឈមដល់កុមារ ហើយជំងឺរបស់ឪពុកម្តាយ ក៏មានផលប៉ះពាល់ដល់សុខភាព និងការអភិវឌ្ឍន៍របស់កុមារនោះផងដែរ។ កុមារដែលរស់នៅជា មួយឪពុកម្តាយដែល មានជំងឺរ៉ាំរ៉ៃគឺទំនងជាទទួលបានសំភារៈជាមូលដ្ឋាន ដូចជា ស្បែកជើង និងសំលៀកបំពាក់ចំនួន ២ ឬក៏ច្រើនកំភ្លែតិចជាងកុមារកំព្រា និងកុមារមិនកំព្រា។ នៅក្នុងឆ្នាំ ២០០៥ ចំនួន៦ភាគរយនៃកុមារមានឪពុកឬម្តាយ ឬក៏ទាំងពីរនាក់បានធ្លាក់ខ្លួនឈឺអស់រយៈពេល ៣ ឬក៏ច្រើនខែ កាលពីឆ្នាំមុន។ ដោយហេតុដូច្នេះហើយទើប មានកុមារម្នាក់ក្នុងចំណោមកុមារ ៧ នាក់ (១៤.៤%)ដែលមានអាយុពី 0 ដល់ ១៧ ឆ្នាំក្លាយជាកុមារកំព្រា ឬកុមារងាយរងគ្រោះដោយសារតែជំងឺរ៉ាំរ៉ៃរបស់ឪពុកឬម្តាយ។

ភាពក្រីក្រធ្ងន់ធ្ងរ បានដើរតួយ៉ាងសំខាន់ក្នុងការបង្កអោយមានភាពងាយរងគ្រោះដល់កុមារ។ កុមាររស់នៅតាមផ្លូវទាំងអស់ត្រូវបានចាត់ទុកស្ថិតក្នុងចំណោមកុមារងាយរងគ្រោះបំផុតនៅក្នុងប្រទេសកម្ពុជា។ មានការប៉ាន់ប្រមាណថាមានកុមារងាយរងគ្រោះបំផុតយ៉ាងតិចចំនួន ២៤ ៧00នាក់ នៅក្នុងប្រទេសកម្ពុជា ភាគច្រើននៅក្នុងទីក្រុងភ្នំពេញ ប៉ៃលិន សៀមរាប និងក្រុងព្រះសីហនុ។

ទិន្នន័យដែលប្រមូលបានតាមរយៈរបាយការណ៍របស់នគរបាលប្រឆាំងនឹងការជួញដូរមនុស្ស បានបង្ហាញថា នៅក្នុងឆ្នាំ ២00៧ មានជនរងគ្រោះនៃការជួញដូរ ការកេងប្រវ័ញ្ច ឬបំពានផ្លូវភេទ/ការចាប់រំលោភ ចំនួន ៧៧១ នាក់ ក្នុងនោះមានកុមារចំនួន ២៧២នាក់ ត្រូវបានជួយសង្គ្រោះ។

*ការយល់ដឹងអំពីស្ថានភាពរបស់កុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍ និងកុមារងាយរងគ្រោះដទៃទៀត និងចំនុចសំខាន់ៗមួយចំនួន:*

- ១៩%នៃកុមារកំព្រា មានជីដូនជីតាដែលជាមេគ្រួសារ
- ៨%នៃកុមារកំព្រាត្រូវបានគេយកមកចិញ្ចឹមជាកូន ជាកូនធម៌ ដោយជាប់ឬក៏មិនជាប់សាច់ញាតិ ទៅនឹងមេគ្រួសារ

- ១៧%នៃកុមារកំព្រា មិនកំពុងរស់នៅជាមួយបងប្អូនបង្កើត ទាំងអស់របស់ពួកគេដែលមាន អាយុក្រោម ១៨ឆ្នាំទេ ធ្វើឱ្យកុមារទាំងនោះកាន់តែមានភាពតានតឹងអារម្មណ៍ បន្ថែមទៅលើការប៉ះទង្គិចដែលមាន ស្រាប់ដោយការបាត់បង់ឪពុកម្តាយ ។
- កុមារដែលបាត់បង់ម្តាយ ទំនងជាមានសភាពក្រិនធ្ងន់ធ្ងរជាងកុមារផ្សេងទៀត
- កុមារដែលម្តាយរបស់គេមានទ្រព្យសម្បត្តិតិចបំផុត មានការប្រឈមមុខ ទៅនឹងការស្លាប់ ៣ដង ច្រើនជាងកុមារដែលម្តាយរបស់គេមានទ្រព្យសម្បត្តិច្រើនបំផុត
- កុមារដែលមានជីវភាពក្រីក្របំផុត ទទួលបានតិចតួចនូវកម្មវិធីបង្ការ ដូចជា ការចាក់ថ្នាំបង្ការ និងការការពារជំងឺដែលបង្ករដោយទឹកមិនស្អាត ដែលនាំអោយ អត្រារស់រានមានកំរិតទាប (ឧទាហរណ៍ មានតែ៥៦%នៃកុមារដែលមាន ជីវភាពក្របំផុត ទទួលបានការចាក់ថ្នាំបង្ការគ្រប់ចំនួន បើធៀបទៅនឹង ចំនួន ៧៦%នៃកុមារដែលមានជីវភាពធូរធារ)
- កុមារ និងយុវវ័យដែលរស់នៅក្នុងគ្រួសារដែលទទួលផលប៉ះពាល់ដោយមេរោគអេដស៍ទំនងជាញុំាអាហារបានតិចជាង និងមានភាពស្រេកឃ្លានច្រើនជាងកុមារ/យុវវ័យដែលរស់នៅក្នុងគ្រួសារដែលមិនទទួលផលប៉ះពាល់ដោយមេរោគអេដស៍
- ភាពពុំមានអាហារគ្រប់គ្រាន់សំរាប់បរិភោគជារៀងរាល់ថ្ងៃ គឺមានការជាប់ទាក់ទងយ៉ាងសំខាន់ជាមួយនឹងការធ្លាក់ទឹកចិត្ត ការថប់បារម្ភ និងភាពតានតឹងអារម្មណ៍ នៃកុមារដែលទទួលផលប៉ះពាល់ដោយមេរោគអេដស៍
- កុមារកំព្រាដែលមានអាយុ ចន្លោះពី ១៣ ទៅ ១៧ឆ្នាំ ពុំបានចូលរៀនជាប់លាប់នោះទេ ហើយវាជាការពិតណាស់ចំពោះទាំងកុមារា និងកុមារី
- ជាទូទៅ កុមារីមានអត្រានៃការចុះឈ្មោះចូលរៀនទាបជាងកុមារា ហើយអត្រានេះ កាន់តែទាបច្រើនជាង នេះទៅទៀតចំពោះកុមារី ដែលទទួលផលប៉ះពាល់ដោយមេរោគអេដស៍
- ការរើសអើង និងការស្រេកឃ្លាន គឺជាសញ្ញាសំខាន់ធំបំផុតចំនួន ២នៃវិបត្តិផ្លូវចិត្តក្នុងចំណោមកុមារដែលទទួលផលប៉ះពាល់ដោយមេរោគអេដស៍
- កុមារដែលមានការបាត់បង់ម្តាយ ទំនងជាបានចុះបញ្ជីកំណើត ឬក៏មានសំបុត្រកំណើតតិចជាងកុមារដទៃទៀត
- គ្រួសារដែលទទួលផលប៉ះពាល់ដោយជំងឺអេដស៍ មានប្រាក់ចំណូលទាបជាងគ្រួសារដែលមិនទទួលផលប៉ះពាល់ដោយជំងឺអេដស៍

- គ្រួសារដែលទទួលផលប៉ះពាល់ដោយមេរោគអេដស៍ ចំណាយច្រើនទៅលើការថែទាំសុខភាព និងចំណាយតិចទៅលើការចំណាយដទៃទៀត បើធៀបទៅនឹងគ្រួសារដែលមិនទទួលផលប៉ះពាល់ដោយមេរោគអេដស៍
- ជំងឺរ៉ាំរ៉ៃរបស់ឪពុកម្តាយ ទាំងនៅក្នុងតំបន់ទីក្រុង និងជនបទគឺជាប់ពាក់ព័ន្ធ ច្រើនទៅ នឹងស្ថានភាព ទ្រព្យសម្បត្តិដែលមានកំរិតទាបហើយគ្រួសារនៅជនបទមានការលំបាកជាង។

តាមការធ្វើផែនទីនៃការឆ្លើយតបនៅពេលបច្ចុប្បន្ននេះ បានចង្អុលបង្ហាញថា ការគ្របដណ្តប់នៃសេវាសង្គមសំរាប់កុមារកំព្រា និងកុមារងាយរងគ្រោះ (OVC)គឺនៅមានកំរិត ហើយកុមារកំព្រា និងកុមារងាយរងគ្រោះជាច្រើននាក់មិនទាន់បានទទួលការគាំទ្រគ្រប់គ្រាន់ពីរដ្ឋាភិបាល និង សង្គមស៊ីវិល នៅ ឡើយទេ ។ ឧទាហរណ៍ មានតែ ៦ ខេត្តប៉ុណ្ណោះ ដែលមានសេវាកាត់បន្ថយផលប៉ះពាល់ដល់កុមារកំព្រា និងកុមារងាយរងគ្រោះ នៅក្នុងចំនួន ៧០%នៃចំនួនឃុំទាំងអស់របស់ខេត្តនិមួយៗ ហើយ ការគ្របដណ្តប់នៃសេវាកាត់បន្ថយផលប៉ះពាល់ដល់កុមារកំព្រាគឺ មានតិចជាង ៣០% នៅក្នុងខេត្តចំនួន ១៣។

ខេត្តមួយចំនួនដែលគួរអោយកត់សំគាល់ ដូចជា ខេត្តកំពង់ចាម សៀមរាប ព្រៃវែង កំពង់ធំ និងកំពង់ស្ពឺ មានចំនួនកុមារកំព្រាខ្ពស់ និងការគ្របដណ្តប់នៃការកាត់បន្ថយផលប៉ះពាល់មានកំរិតទាប។ ខេត្តទាំងនេះ អាចត្រូវបានគេចាត់ទុកជាខេត្តអាទិភាពសំរាប់ការពង្រីកការផ្តល់សេវា។

## ផែនការសកម្មភាពជាតិ

### ការបង្កើតឡើងនូវផែនការសកម្មភាពជាតិ

ផែនការសកម្មភាពជាតិនេះ ត្រូវបានរៀបចំឡើងដោយមានការចូលរួមចំណែកយ៉ាងទូលំទូលាយពីសំណាក់រដ្ឋាភិបាល និង សង្គមស៊ីវិល ដោយរាប់បញ្ចូលទាំងអង្គការក្រៅរដ្ឋាភិបាល និង កុមារ ព្រមទាំងដៃគូអភិវឌ្ឍន៍អន្តរជាតិជាច្រើនទៀត។ ផែនការនេះរៀបចំឡើងដោយផ្អែកលើអនុសាសន៍ និង មេរៀនជាបទពិសោធន៍ដែលទទួលបានពីការវាយតម្លៃស្ថានភាព និង ការឆ្លើយតប ព្រមទាំង ការរៀបចំផែនទីសេវា កាត់បន្ថយផលប៉ះពាល់ចំពោះ OVC ដែលបានបង្កើតឡើងនៅឆមាសទី១ ឆ្នាំ២០០៧ ហើយ ដែលឯកសារទាំងពីរនេះ ត្រូវបានរៀបចំបោះពុម្ពផ្សាយនៅពេលជាមួយគ្នា និងផែនការសកម្មភាពជាតិនេះ[5] ។ ក្រុមការងារថ្នាក់ជាតិ ពហុផ្នែក ស្តីពីកុមារកំព្រា និង កុមារងាយរងគ្រោះ ដឹកនាំដំណើរការទូទៅនៃការរៀបចំឯកសារទាំងនេះ ដោយមានជំនួយពី គណកម្មការដឹកនាំ ទីប្រឹក្សាអន្តរជាតិម្នាក់ និង ទីប្រឹក្សាក្នុងស្រុកពីរនាក់។

ផ្អែកតាមរបកគំហើញ និង អនុសាសន៍ ទទួលបានពីការវាយតម្លៃស្ថានភាព និង គោលការណ៍ណែនាំរបស់ *ក្របខណ្ឌការងារសកលសំរាប់ការការពារ ថែទាំ និង គាំទ្រ ដល់ OVC ដែលកំពុងរស់នៅក្នុងពិភពនៃមេរោគអេដស៍ និង ជំងឺអេដស៍* សេចក្តីព្រាងផែនការមួយត្រូវបានបង្កើតឡើង។ សេចក្តីព្រាងផែនការនេះបានទទួលនូវមតិយោបល់កែលំអបន្ថែមតាមរយៈ សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ខេត្ត ចំនួនពីរដែល ត្រូវបានរៀបចំធ្វើ នៅក្នុងខេត្តបាត់ដំបង និង ក្រុងព្រះសីហនុ និង សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិមួយទៀត នៅក្នុងទីក្រុងភ្នំពេញ ក្នុងខែមិថុនា ឆ្នាំ២០០៧។

អ្នកចូលរួមនៅក្នុងសិក្ខាសាលាបានផ្តល់ជូននូវព័ត៌មានត្រឡប់ និង ធ្វើការបញ្ជាក់ទៅលើភាពស៊ីសង្វាក់របស់ចក្ខុវិស័យ និង គោលដៅ ព្រមទាំងផ្តល់យោបល់លំអិតទៅលើយុទ្ធសាស្ត្រនិមួយៗ គោលបំណងសកម្មភាព ភ្នាក់ងារដឹកនាំ និង ដៃគូសំខាន់ៗ។ សូចនាករ និង ចំនុចដៅ ត្រូវបានកំនត់ដោយមាន កិច្ចពិគ្រោះយោបល់ជាមួយភ្នាក់ងារដឹកនាំ ព្រមជាមួយនឹងជំនួយបច្ចេកទេសពី UNAIDS ហើយសូចនាករ

---

[5] សេចក្តីពង្រាងលើកុមារកំព្រា កុមារទទួលរងផលប៉ះពាល់ដោយមេរោគអេដស៍ និង ជំងឺអេដស៍ និង កុមារងាយរងគ្រោះដទៃផ្សេងទៀតក្នុងប្រទេសកម្ពុជា: ការវិភាគស្ថានភាព និង ការឆ្លើយតប ២០០៧ និង សេចក្តីពង្រាងលើការរៀបចំផែនទីសដែលឆ្លើយតបទៅនិង ការការពារ ការថែទាំ និងការ គាំទ្រកុមារកំព្រា និងងាយរងគ្រោះ កុមារនៅក្នុងប្រទេសកម្ពុជា

និងចំនុចដៅទាំងនោះមានលក្ខណៈស្របគ្នាទៅនឹង ចំនុចដៅសំរាប់ការទទួលបាន ជាសកល ចំនុចដៅរបស់ NCHADS និង ចំនុចដៅដែលបង្កើតឡើង ក្រោមផែនការយុទ្ធសាស្រ្តជាតិ សំរាប់ការឆ្លើយតប ទូលំទូលាយនិង ពហុវិស័យ ចំពោះមេរោគអេដស៍ និង ជំងឺអេដស៍ ២០០៦-២០១០។

ឈ្មោះរបស់អង្គការនិង អ្នកចូលរួម ក្នុងសិក្ខាសាលានៅខេត្របាត់ដំបង ក្រុងព្រះសីហនុ និងភ្នំពេញ មានចែងក្នុងឧបសម្ព័ន្ធ ទី១។

## គោលការណ៍ណែនាំ

### អនុសញ្ញាស្តីពីសិទ្ធិកុមារ បានផ្តល់ជាមគ្គុទ្ទេសក៏ដល់ផែនការសកម្មភាពជាតិ

កម្ពុជា គឺជាប្រទេសហត្ថលេខីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC) ដែលជាឯកសារអន្តរជាតិ ពេញលេញ បរិបូរណ៏មួយទាក់ទងទៅនឹងសិទ្ធិកុមារ។ CRC បានទទួលស្គាល់ថា កុមារគឺជាសិទ្ធិវន្ត ហើយក៏ជា អ្នកចូលរួមផងដែរ ពួកគេពុំមែនគ្រាន់តែជា អ្នកទទួលសេវា រឺ ជាអ្នកទទួលផលប្រយោជន៏ ពីវិធានការ ការពារចំពោះពួកគេតែប៉ុណ្ណោះនោះទេ។

អនុសញ្ញាស្តីពីសិទ្ធិកុមារ បានបញ្ជាក់យ៉ាងច្បាស់ថា គ្រួសារមានការទទួលខុសត្រូវចម្បង ក្នុងការការពារ និង ថែទាំកុមារ ចំណែកឯរដ្ឋាភិបាលវិញទទួលខុសត្រូវ ការពារ ថែរក្សា និង គាំទ្រ ទំនាក់ទំនងរវាងកុមារ និង គ្រួសារ។ អនុសញ្ញាក៏បានបញ្ជាក់ផងដែរអំពី ការទទួលខុសត្រូវរបស់រដ្ឋ ក្នុងការផ្តល់កិច្ចការពារ ជាពិសេស ចំពោះកុមារដែលខ្វះខាតភាពកក់ក្តៅក្នុងបរិស្ថានគ្រួសាររបស់ពួកគេ។

តំលៃសំខាន់របស់ CRC គឺបានផ្តល់ការណែនាំសំរាប់ការអនុវត្តន៏ និង ការត្រួតពិនិត្យតាមដាន ផែនការ សកម្មភាពជាតិនេះ។ ហេតុដូច្នេះ ផែនការនេះអនុវត្តន៏ទៅតាមគោលការណ៏ចំនួន៤ ដូចខាងក្រោមៈ

- ការគ្មានការរើសអើង (មាត្រាទី២)
- ឧត្តមប្រយោជន៏របស់កុមារ (មាត្រាទី៣)
- សិទ្ធិក្នុងការទទួលបាននូវ ការរស់រានមានជីវិត សុខមាលភាព និង ការអភិវឌ្ឍន៏ (មាត្រាទី៦)
- កុមារមានសិទ្ធិចូលរួមក្នុងការសំរេចចិត្តទាំងឡាយណាដែលមានផលប៉ះពាល់ដល់ពួកគេ (មាត្រាទី១២)

**រាល់កិច្ចខិតខំប្រឹងប្រែងទាំងឡាយ គួរតែបានរួមចំណែក ធ្វើឱ្យមានការផ្លាស់ប្តូរមួយគួរឱ្យកត់សំគាល់ និងយូរអង្វែង ដល់ជីវិតរបស់កុមារ**

រាល់កិច្ចខិតខំប្រឹងប្រែងទាំងឡាយ ទាំងកិច្ចខិតខំប្រឹងប្រែងរបស់បុគ្គល និង សមូហភាព គួរតែតំរង់ឆ្ពោះទៅការ ធ្វើឱ្យមានការផ្លាស់ប្តូរមួយជាវិជ្ជមាន គួរឱ្យកត់សំគាល់ និង យូរអង្វែងដល់ជីវិតរបស់កុមារ។ កិច្ចការនេះទាមទារឱ្យមាន ការយល់ច្បាស់អំពីផលប្រយោជន៍ដែលបានគ្រោងទុក និង មិនបានគ្រោងទុករបស់កម្មវិធី ដែលកុមារអាចនឹងទទួលបាន ព្រមទាំងកសាងនូវសមត្ថភាព ក្នុងការវិភាគ ក៏ដូចជាការអនុវត្តន៍គោលនយោបាយផងដែរ។

**សមធម៌យេនឌ័រ**

យេនឌ័រ ការអភិវឌ្ឍន៍ និង ការរីករាលដាលនៃមេរោគអេដស៍ មានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយគ្នា ហើយទំនាក់ទំនងនេះ បានស្តែងឱ្យឃើញយ៉ាងច្បាស់លាស់នៅក្នុងប្រទេសកម្ពុជា។ ស្ត្រី និង កុមារី ងាយនឹងទទួលរងគ្រោះពីការឆ្លងមេរោគអេដស៍ និង ផលប៉ះពាល់នៃមេរោគអេដស៍/ជំងឺអេដស៍ ជាងបុរស អាស្រ័យដោយ ពួកគេមានឋានៈនៅក្នុងគ្រួសារ និង សង្គមទាបជាងបុរស។ វិសមភាពយេនឌ័រ ចាំបាច់ត្រូវលើកឡើង និង ធ្វើការកែសំរួល ដើម្បីឱ្យការឆ្លើយតបថ្នាក់ ជាតិប្រកបទៅដោយប្រសិទ្ធិភាពជាក់លាក់។

**ការចូលរួមរបស់កុមារ**

កុមារ និង អ្នកថែទាំរបស់ពួកគេ ពុំមែនគ្រាន់តែជាអ្នកដែលទទួលនូវសេវាគាំទ្រផ្នែកសង្គមតែប៉ុណ្ណោះទេ ពួកគេក៏ជាផ្នែកមួយនៃដំណោះស្រាយបញ្ហាផងដែរ។ កិច្ចខិតខំប្រឹងប្រែង បទពិសោធន៍ និង ការយល់ដឹងជ្រៅជ្រះរបស់ពួកគេ សុទ្ធសឹងតែមានតំលៃ សំរាប់គ្រប់រូបភាពទាំងអស់នៃការឆ្លើយតបថ្នាក់ជាតិ គិតចាប់ពី ការបង្កើតគោលនយោបាយ រហូតដល់ការរៀបចំផែនការកម្មវិធី ការអនុវត្តន៍ផែនការ ការសិក្សា ស្រាវជ្រាវ ការត្រួតពិនិត្យតាមដាន និង វាយតំលៃ។ ជាគោលការណ៍ ប្រសិនបើ OVC ត្រូវការ ឱ្យមានអ្នកតំណាងសំរាប់ចូលរួមនៅក្នុងវេទិកាដើម្បីធ្វើការសំរេចចិត្តលើបញ្ហាអ្វីមួយ ពួកគេគួរមាន អ្នកតំណាងដែលជាកុមារ/OVC។ ឆ្លងតាមរយៈការចូលរួមនៅក្នុងសកម្មភាពអភិវឌ្ឍន៍ កុមារតែងទទួលបាន នូវជំនាញ និង ទំនុកចិត្ត ដែលមិនត្រឹមតែជួយដល់ពួកគេនាពេលបច្ចុប្បន្ននោះទេ ថែមទាំងអាចជួយដល់ ពួកគេសំរាប់ពេលអនាគតថែមទៀតផង។

**វិធីដោះស្រាយដែលផ្តោតលើកុមារ**

វិធីដោះស្រាយដែលផ្តោតលើកុមារ ធានាថាកុមារត្រូវគេទទួលស្គាល់ថាជាអតិថិជន ហើយគួរតែជាមនុស្សសំខាន់ ក្នុងការទទួលផល ពីរាល់កិច្ចខិតខំប្រឹងប្រែងទាំងអស់។ កុមារអាចចង់ពិភាក្សាអំពីបញ្ហាដែលមនុស្សពេញវ័យមិនចង់លើកយកមកនិយាយដូចជាបញ្ហាការរំលោភបំពាន។ ភាពបើកចំហរកាន់តែទូលំទូលាយជួយឱ្យគ្រួសារ និងសហគមន៍លើកឡើងនូវបញ្ហាសំខាន់ៗដែលប៉ះពាល់ដល់កុមារហើយភាពបើកចំហរនេះតែងធ្វើឱ្យទំនាក់ទំនងមានភាពប្រសើរឡើងជានិច្ច។ នៅពេលដែលទទួលបានការគាំទ្រ និងឱកាសកុមារអាចមានភាពប៉ិនប្រសប់ក្នុងការអប់រំកុមារដទៃទៀត និងមនុស្សពេញវ័យលើបញ្ហាសំខាន់ៗ។ វិធីដោះស្រាយដែលផ្តោតលើកុមារធានាថាកុមារ នឹងទទួលបានលក្ខណៈងាយស្រួលក្នុងការបង្ហាញដោយត្រឹមត្រូវនូវអ្វីដែលជាតំរូវការរបស់ពួកគេនៅក្នុងវេទិកាថ្នាក់សហគមន៍ ថ្នាក់ជាតិ និងអន្តរជាតិ ដោយពុំមានការកេងប្រវ័ញ្ច។

**ចក្ខុវិស័យ:**

សង្គមកម្ពុជាមួយ ដែលកុមារគ្រប់រូបទទួលបាននូវ ការការពារ ថែទាំ និង គាំទ្រគ្រប់គ្រាន់ដើម្បីអភិវឌ្ឍន៍ឱ្យឈានដល់សក្តានុពលពេញលេញរបស់ពួកគេ ក្នុងបរិស្ថានមួយដែលពោរពេញទៅដោយការគាំទ្រ។

**គោលដៅ:**

គោលដៅផែនការសកម្មភាពជាតិពហុផ្នែករយៈពេល៣ឆ្នាំ គឺដើម្បីពង្រឹងកិច្ចសំរបសំរួល ប្រព័ន្ធ និង ការគ្របដណ្តប់ ព្រមទាំងគុណភាពសេវាដែលចាំបាច់ក្នុងការកាត់បន្ថយផលប៉ះពាល់នៃមេរោគអេដស៍ចំពោះជីវិត និង អនាគតកុមារកម្ពុជា និងដោះស្រាយផងដែរ នូវបញ្ហាសំខាន់ៗទាំងឡាយនៃកុមារងាយរងគ្រោះ។

**ទំនាក់ទំនងជាមួយផែនការ យុទ្ធសាស្ត្រ និង ចំនុចដៅជាតិដទៃផ្សេងទៀត**

ផែនការសកម្មភាពជាតិ នឹងរួមចំណែកក្នុងការសំរេចឱ្យបាននូវ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDG) និង ចំនុចដៅដទៃផ្សេងទៀត ជាពិសេសចំនុចដៅទាំងឡាយណាដែលទាក់ទងទៅនឹង ការធ្វើឱ្យប្រសើរឡើងដល់ជីវិតកុមារ និង អ្នកថែទាំរបស់ពួកគេ ដែលក្នុងនោះរួមមាន:

CMDG 1: លុបបំបាត់ភាពក្រីក្រ និង ភាពអត់ឃ្លានធ្ងន់ធ្ងរ

CMDG 2: សំរេចឱ្យបាននូវការអប់រំមូលដ្ឋានជាសកលដែលមានរយៈពេល៩ឆ្នាំ

CMDG 4: កាត់បន្ថយអត្រាស្លាប់របស់កុមារ

CMDG 5: ធ្វើឱ្យប្រសើរឡើងនូវសុខភាពរបស់មាតា

CMDG 6: បញ្ឈប់ និង កាត់បន្ថយការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍

ផែនការសកម្មភាពជាតិ នឹងរួមចំណែកក្នុងការសំរេចឱ្យបាននូវ គោលដៅរបស់ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបចំពោះមេរោគអេដស៍/ជំងឺអេដស៍លើកទី II ( NSP II ) ជាពិសេសនៅក្នុងយុទ្ធសាស្ត្រទី៧ដែលបានចែងថាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា (MOSVY) នឹងផ្តល់ភាពជាអ្នកដឹកនាំ ក្នុងការបង្កើតគោលនយោបាយយុទ្ធសាស្ត្រ និង គោលការណ៍ណែនាំសំរាប់សេវាកាត់បន្ថយផលប៉ះពាល់ចំពោះកុមារ គ្រួសារ និង សហគមន៍ និងបង្កើន ការគ្របដណ្តប់ និង គុណភាពលើកិច្ចអន្តរាគមន៍ ចំពោះ OVC និង គ្រួសារដែលទទួលផល ប៉ះពាល់ដោយមេរោគអេដស៍ និង ជំងឺអេដស៍ [6] ។ NSPII ក៏មានគោលដៅមួយដើម្បីបង្កើន កិច្ចគាំទ្រផ្នែកអាហាររូបត្ថម្ភដល់គ្រួសារដែលទទួលផលប៉ះពាល់ដោយមេរោគអេដស៍និងជំងឺអេដស៍ដែលត្រូវបានធ្វើឱ្យមានលក្ខណៈច្បាស់លាស់និងពិតប្រាកដនៅក្នុងផែនការនេះជាមួយនឹងការឯកភាពនៅថ្នាក់ជាតិទៅលើកញ្ចប់អប្បបរមាសំរាប់ជំនួយផ្នែកស្បៀងអាហារ ។

សូចនាករ និង ចំណុចដៅសំរាប់ការទទួលបានជាសកល ដែលផ្តោតសំខាន់ទៅលើ OVC រួមមានៈ

- ចំនួនភាគរយនៃគ្រួសារដែលមានសមាជិកជា OVC និង ដែលបានទទួលកញ្ចប់ អប្បបរមាសំរាប់ការថែទាំ ( ចំណុចដៅសំរាប់ឆ្នាំ២០០៨- ៣០% និង ឆ្នាំ២០១០ - ៥០%)
- ចំនួនភាគរយនៃឃុំ/សង្កាត់ដែលយ៉ាងហោចណាស់ មានអង្គការចំនួនមួយ ផ្តល់ការថែទាំ និង គាំទ្រដល់គ្រួសារដែលមានសមាជិកជា OVC ( ចំណុចដៅសំរាប់ឆ្នាំ២០០៨ - ៥០% និង ឆ្នាំ២០១០ - ១០០% )[7]

[6] អាជ្ញាធរជាតិប្រឆាំងនឹងជំងឺអេដស៍ (2005). "ផែនការយុទ្ធសាស្ត្រជាតិ សំរាប់ការឆ្លើយតបពហុផ្នែកដែលមានលក្ខណៈពេញលេញ ចំពោះមេរោគអេដស៍/ជំងឺអេដស៍ ២០០៦-២០១០" កម្ពុជា

[7] កម្មវិធីសហការណ៍គាំទ្ររបស់ UNAIDS 2006-2010; ដំណើរការលួន - ការពិគ្រោះទុកជាមុនរបស់សង្គមស៊ីវិល លើការទទួលបានជាសកល - ផែនទីមាគាររបស់ប្រទេសកម្ពុជា សំរាប់ការឆ្លើយតបជាតិ ចំពោះមេរោគអេដស៍/ជំងឺអេដស៍ . HACC, ថ្ងៃទី២៣ ខែវិច្ឆិកា ២០០៦

**ខេត្តអាទិភាព**

អាស្រ័យដោយវត្តមានរបស់មេរោគអេដស៍ក្នុងចំណោមចំនួនប្រជាជនទូទៅ និង ចំនួនដ៏ច្រើនលើសលប់របស់ OVC ព្រមជាមួយនឹងចំនួនតិចតួចនៃការគ្របដណ្តប់លើសេវាកាត់បន្ថយផលប៉ះពាល់ ខេត្តអាទិភាពសំរាប់ការពង្រីកសេវា រួមមាន កំពង់ចាម សៀមរាប ព្រៃវែង កំពង់ធំ និង កំពង់ស្ពឺ ។

**គោលបំនងរបស់ផែនការសកម្មភាពជាតិ**

ផែនការសកម្មភាពជាតិពហុផ្នែករយៈពេល៣ឆ្នាំ នឹង:

1. ផ្តល់នូវរចនាសម្ព័ន្ធក្របខណ្ឌការងារ ដើម្បីសំរបសំរួលការឆ្លើយតបឱ្យមានលក្ខណៈងាយស្រួល និង ប្រកបដោយប្រសិទ្ធិភាព ចំពោះកុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍ឬកុមារងាយរងគ្រោះដោយក្របខណ្ឌការងារនេះនឹងបង្កើតឱ្យមានឡើងនូវការផ្លាស់ប្តូរមួយជាវិជ្ជមាន យូរអង្វែង និង គួរឱ្យកត់សំគាល់ សំរាប់ជីវិតរបស់កុមារ
2. ផ្តល់នូវគោលការណ៍ណែនាំ និង ក្របខណ្ឌការងារ សំរាប់ការបង្កើតកម្មវិធី ការរៀបចំ និង កំណត់កាលវិភាគសកម្មភាព រវាងភ្នាក់ងារផ្សេងៗដើម្បីកាត់បន្ថយកិច្ចខិតខំប្រឹងប្រែងស្ទួនគ្នាដដែលៗ និង ធានាឱ្យមាននូវវិធីដោះស្រាយរួមនិងស្របគ្នាមួយ
3. ដើរតួជាក្របខណ្ឌយោងមួយដែលមានសូចនាករ និង ចំណុចដៅរួម ដែលបានព្រមព្រៀងគ្នាដើម្បីវាស់ស្ទង់សមិទ្ធិផលដែលកម្ពុជាសំរេចបាន ក្នុងការកាត់បន្ថយផលប៉ះពាល់នៃមេរោគអេដស៍ និង ជំងឺអេដស៍លើកុមារ
4. ត្រូវបានប្រើប្រាស់ជាឯកសារស្នូល សំរាប់ការកៀងគរ និងផ្តល់ធនធានប្រកបដោយប្រសិទ្ធិភាព ដល់កម្មវិធីគាំទ្រ OVC និង សកម្មភាពអាទិភាពដទៃទៀតនៅទូទាំងប្រទេស
5. ជាក្របខណ្ឌការងារជាតិរួមមួយសំរាប់ពង្រឹង និង ធ្វើឱ្យមានការឯកភាពក្នុងការផ្តល់អន្តរាគមន៍ជាតិពហុផ្នែក ដល់គ្រប់បណ្តាស្ថាប័នពាក់ព័ន្ធទាំងអស់ ។

**យុទ្ធសាស្ត្រគន្លឹះទាំង៥:**

ដើម្បីសំរេចបាននូវគោលដៅ និង ចក្ខុវិស័យ ផែនការសកម្មភាពជាតិ នឹងប្រើប្រាស់ យុទ្ធសាស្ត្រគន្លឹះចំនួន៥ ដែលបានរៀបចំនិងកែសំរួលពី *ក្របខណ្ឌការងារសកលសំរាប់ការការពារ ថែទាំ និង គាំទ្រ កុមារកំព្រា និង កុមារងាយរងគ្រោះដែលកំពុងរស់នៅក្នុងពិភពនៃមេរោគអេដស៍និងជំងឺអេដស៍ ។*

យុទ្ធសាស្ត្រគន្លឹះសំរាប់ប្រទេសកម្ពុជារួមមាន:

១. ពង្រឹង សមត្ថភាពគ្រួសារ ដើម្បីការពារ និង ថែទាំកុមារកំព្រា និង កុមារងាយរងគ្រោះ ដោយពន្យារជីវិតឪពុកម្តាយ និង ផ្តល់នូវការគាំទ្រផ្នែកសេដ្ឋកិច្ច ចិត្តសង្គម និង ការគាំទ្រដទៃផ្សេងទៀត

២. បំផុសចលនា និង គាំទ្រ ការឆ្លើយតបក្នុងសហគមន៍ដែលការពារ ថែទាំ និង គាំទ្រ OVC និងអ្នកថែទាំរបស់ពួកគេ

៣. ធានាថា កុមារកំព្រា និង កុមារងាយរងគ្រោះ ទទួលបាននូវ សេវាសំខាន់ៗ ដែលរួមមាន ការអប់រំ ការថែទាំសុខភាព ការចុះបញ្ជីកំណើត និង សេវាដទៃទៀតផ្សេងទៀត

៤. ធានាថា កុមារងាយរងគ្រោះទទួលបានការការពារ តាមរយៈគោលនយោបាយ និង នីតិកម្ម

៥. បង្កើតឱ្យមានឡើងនូវ បរិស្ថានគាំទ្រមួយ សំរាប់ការឆ្លើយតបមួយដែលទទួលបានការសំរបសំរួល និង ប្រកបដោយប្រសិទ្ធិភាព ចំពោះកុមារដែលទទួលផលប៉ះពាល់ រឺ ងាយរងគ្រោះដោយមេរោគអេដស៍ និង ជំងឺអេដស៍ ។

**យុទ្ធសាស្ត្រជាក់លាក់**

***យុទ្ធសាស្ត្រគន្លឹះទី១: ពង្រឹងសមត្ថភាពគ្រួសារ ដើម្បីការពារ និង ថែទាំកុមារកំព្រា និង កុមារងាយរងគ្រោះ***

គ្រួសារគឺជាក្តីសង្ឃឹមដ៏ប្រសើរបំផុតសំរាប់កុមារងាយរងគ្រោះ ប៉ុន្តែគ្រួសារដែលទទួលផលប៉ះពាល់ដោយមេរោគអេដស៍ រឺ កំពុងជួបប្រទះនូវកង្វះខាតធ្ងន់ធ្ងរផ្នែកហិរញ្ញវត្ថុ រឺ អសន្តិសុខស្បៀង អាចទាមទារ ឱ្យមានការជួយគាំទ្រពីប្រភពខាងក្រៅ សំរាប់សេចក្តីត្រូវការក្នុងការរស់នៅភ្លាមៗ និង សេចក្តីត្រូវការសំរាប់ការរស់នៅយូរអង្វែងទៅមុខទៀត ។

គ្រួសារ OVC ទាមទារឱ្យមានកិច្ចគាំទ្រគ្រប់បែបយ៉ាង ដើម្បីឱ្យពួកគេអាចមានលទ្ធភាពក្នុងការផ្ដល់ការការពារ ថែទាំ និង គាំទ្រ ដល់កុមារ។ យុទ្ធសាស្ត្រគន្លឹះទី១ រួមមានគោលបំណងជាក់លាក់ចំនួន៦ ដែលគោលបំណងនិមួយៗ អាចសំរេចទៅបាន តែដោយសារឆ្លងតាមការអនុវត្តន៍សកម្មភាពពាក់ព័ន្ធមួយចំនួនប៉ុណ្ណោះ។ វាចាំបាច់ណាស់ដែល សកម្មភាពនិមួយៗត្រូវបានអនុវត្ត តាមរយៈសេវាឆ្លើយតបរួមបញ្ចូលគ្នាមួយ។

**គោលបំណងជាក់លាក់:**

១.១ ធ្វើឱ្យប្រសើរឡើងផ្នែកជីវភាពនិងសន្តិសុខផ្នែកសេដ្ឋកិច្ចរបស់គ្រួសារដែលគាំទ្រ OVC

១.២ ផ្ដល់ នូវកិច្ចគាំទ្រផ្នែកចិត្តសង្គម ដែលប្រកបដោយគុណភាព ដល់កុមារ ដែលទទួលផលប៉ះពាល់ដោយមេរោគអេដស៍ និង អ្នកថែទាំរបស់ពួកគេ

១.៣ ពង្រឹង និង គាំទ្រសមត្ថភាពថែទាំកុមារ

១.៤ ការពារសិទ្ធិរបស់កុមារពេលបច្ចុប្បន្ន និង តទៅអនាគត

១.៥ ពន្យារជីវិតរបស់ឪពុកម្ដាយដែលមានផ្ទុកមេរោគអេដស៍

១.៦ កាត់បន្ថយការឆ្លងរាលដាលថ្មីៗ ក្នុងចំណោមយុវជនវ័យក្មេង តាមរយៈការពង្រឹងជំនាញបំណិនជីវិតរបស់ពួកគេ

***យុទ្ធសាស្ត្រគន្លឹះទី២: បំផុសចលនា និង គាំទ្រ <u>ការឆ្លើយតបក្នុងសហគមន៍</u> ដើម្បីថែទាំ ការពារ និង គាំទ្រ ដល់ កុមារកំព្រា និង កុមារងាយរងគ្រោះ***

OVC រស់នៅក្នុងសហគមន៍ ហើយសហគមន៍ផ្ដល់ឱ្យពួកគេនូវការគាំទ្រ ទាន់ពេល វេលា និង ស្របទៅនឹងសេចក្ដីត្រូវការរបស់ពួកគេបំផុត។ មេរៀនជាបទពិសោធន៍ បានបង្ហាញ ឱ្យឃើញអំពីសេចក្ដីត្រូវការឱ្យមាននូវវិធីដោះស្រាយដែលមានលក្ខណៈជាប្រព័ន្ធមួយ សំរាប់ការបំផុសចលនា និងការគាំទ្រនៅក្នុងសហគមន៍។ ដើម្បីឱ្យកិច្ចការនេះសំរេចទៅបាន យុទ្ធសាស្ត្រគន្លឹះទី២ បានដាក់ចេញនូវគោលបំណងជាក់លាក់ចំនួន៣។

**គោលបំណងជាក់លាក់:**

២.១ ជំរុញឱ្យមេដឹកនាំភូមិ/ឃុំ/សង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ និងមេដឹកនាំសហគមន៍ផ្សេងទៀតបានចូលរួមក្នុងការ ឆ្លើយតបចំពោះសេចក្ដីត្រូវការភ្លាមៗរបស់ OVC

២.២ ជំរុញឱ្យសមាជិកក្នុងសហគមន៍ ជជែកគ្នាដោយបើកចំហរ ត្រឹមត្រូវ និង ដោយពុំមានការ

រីសអើងចំពោះ មេរោគអេដស៍ និង ជំងឺអេដស៍

២.៣ បំផុសចលនាសមាជិកក្នុងសហគមន៍ ឱ្យផ្តល់នូវការគាំទ្រ ដែលប្រកបដោយប្រសិទ្ធិភាពខ្ពស់ ទាន់ពេលវេលា និង ការគាំទ្រដែលពោរពេញទៅដោយការអាណិតអាសូរដល់ OVC និង គ្រួសារដែលទទួលផលប៉ះពាល់ដោយមេរោគអេដស៍ ។

***យុទ្ធសាស្រ្តគន្លឹះទី៣: ធានាថា កុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍ និង កុមារងាយរងគ្រោះដទៃទៀត ទទួលបាននូវ <u>សេវាសំខាន់ៗ</u>***

ការទទួលបាននូវសេវាសំខាន់ៗ អាចជួយការពារសិទ្ធិក្នុងការរស់រានមានជីវិត និង ការអភិវឌ្ឍន៏របស់កុមារ។ OVC ទាមទារឱ្យទទួលបាននូវសេវាទាំងនេះយ៉ាងពេញលេញ និង ដោយឥតគិតថ្លៃ។ យុទ្ធសាស្រ្តគន្លឹះនេះ រួមមានគោលបំណងជាក់លាក់ចំនួន៤ ដែលផ្តោតសំខាន់លើ ការបង្កើននិងពង្រីកវិសាលភាពគ្របដណ្តប់នៃសេវា កញ្ចប់អប្បបរមា។

**គោលបំណងជាក់លាក់:**

៣.១ បង្កើនសន្តិសុខស្បៀងក្នុងចំណោមកុមារកំព្រា កុមារទទួលផលប៉ះពាល់ដោយ មេរោគអេដស៍ កុមារងាយរងគ្រោះដទៃទៀត និង អ្នកថែទាំរបស់ពួកគេ

៣.២ កាត់បន្ថយអត្រាឈឺ និង ស្លាប់របស់កុមារ តាមរយៈការផ្តល់នូវកិច្ចគាំទ្រដល់ OVC និង អ្នកថែទាំរបស់ពួកគេ ដើម្បីឱ្យពួកគេអាចទទួលបាននូវសេវាសុខភាព

៣.៣ គាំទ្រ OVC ដោយរួមទាំងកុមារទទួលផលប៉ះពាល់ដោយមេរោគអេដស៍ ឱ្យបាន ទទួលការអប់រំក្នុងប្រព័ន្ធរយៈពេល៩ឆ្នាំដោយឥតគិតថ្លៃ

៣.៤ ផ្តល់ឱ្យកុមារដែលត្រូវការឱ្យមាននូវការថែទាំជំនួស អាចទទួលបាននូវជំរើសសំរាប់ការថែទាំជំនួស សមស្រប និង ប្រកបដោយសុវត្ថិភាព

***យុទ្ធសាស្រ្តគន្លឹះទី៤: ធានាថា កុមារងាយរងគ្រោះទទួលបានការការពារ តាមរយៈគោលនយោបាយ និង នីតិកម្ម***

ខណៈពេលដែលគ្រួសារមានការទទួលខុសត្រូវបឋម ក្នុងការថែទាំ និង ការពារកុមារ រាជរដ្ឋាភិបាលក៏ត្រូវមានការទទួលខុសត្រូវខ្ពស់ ក្នុងការការពារ និង ធានានូវសុខមាលភាពរបស់ពួកគេផងដែរ [8] ។ កម្ពុជាមានច្បាប់ បទបញ្ញត្តិ និងបានផ្តល់សច្ចាប័នអនុសញ្ញាអន្តរជាតិមួយចំនួន ដែលអាចយកមកប្រើប្រាស់ដើម្បីការពារកុមារពីការរំលោភបំពាន ការកេងប្រវ័ញ្ច និងការរើសអើង។

ក្នុងរយៈពេលពាឆ្នាំខាងមុខ ផែនការសកម្មភាពជាតិនេះនឹងដឹកនាំសកម្មភាព ដើម្បីពង្រឹងសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការលើកកំពស់ប្រព័ន្ធថែទាំកុមារដោយញាតិសន្តាន និង ដោយឪពុកម្តាយធម៌ , បង្កើតឱ្យមានឡើង ត្រួតពិនិត្យតាមដាន និង ពង្រឹងការអនុវត្តន៍បទដ្ឋានអប្បបរមាសំរាប់អ្នកផ្តល់សេវា , កសាងសមត្ថភាព និង ភាពទទួលខុសត្រូវរបស់មន្ត្រីជំនាញដែលធ្វើការងារជាមួយកុមារ ព្រមទាំងបង្កើនសមត្ថភាពក្នុងការ ផ្លាស់ប្តូរពីការថែទាំកុមារនៅតាមស្ថាប័ន ឱ្យទៅជាសេវាថែទាំជំនួសក្នុងសហគមន៍វិញ។

**គោលបំណងជាក់លាក់:**

៤.១ ធានាថាកុមារទទួលបានការការពារពីអំពើរំលោភបំពាន ការកេងប្រវ័ញ្ច ភាពព្រងើយកន្តើយ និង ការជួញដូរ តាមរយៈច្បាប់ ស្តីពីកិច្ចការពារកុមារ ច្បាប់ស្តីពីយុត្តិធម៌អនិតិជន និងកម្មវិធីដែលពាក់ព័ន្ធមួយចំនួនទៀត

៤.២ លើកកំពស់សមត្ថភាពរបស់ MOSVY ក្នុងការការពារ ថែទាំ និង គាំទ្រ OVC

***យុទ្ធសាស្ត្រគន្លឹះទី៥: បង្កើតឱ្យមានឡើងនូវ <u>បរិស្ថានអំណោយផលមួយ</u> សំរាប់ការឆ្លើយតបដែលទទួលបាននូវការសំរបសំរួល និង ប្រកបដោយប្រសិទ្ធិភាព ដើម្បីកាត់បន្ថយផលប៉ះពាល់នៃមេរោគអេដស៍ និង ជំងឺអេដស៍ចំពោះកុមារកំព្រា និង កុមារងាយរងគ្រោះដទៃផ្សេងទៀត***

[8] UNICEF (2004) ក្របខណ្ឌការងារសំរាប់ការការពារ ថែទាំ និង គាំទ្រកុមារកំព្រា និង កុមារងាយរងគ្រោះដែលកំពុងរស់នៅក្នុងពិភពនៃមេរោគអេដស៍ និង ជំងឺអេដស៍ , ទំព័រទី១៨

*“ កាលគ្រាដំបូង ការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ បានធ្វើឱ្យមានការភ័យខ្លាច ភាពព្រងើយកន្តើយ និង ការបដិសេធន៍មិនទទួលស្គាល់ ដែលទាំងអស់នេះបាន នាំឱ្យឈានទៅដល់ភាពស្ងៀមស្ងាត់ និង អសកម្ម អំពីសំណាក់ផ្នែករដ្ឋាភិបាល និង ស្ថាប័នពាក់ព័ន្ធដទៃផ្សេងទៀត ក៏ដូចជាការរើសអើង និង ភាពមាក់ងាយ ទៅលើអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍។ កុមារកំព្រា និង កុមារងាយរងគ្រោះ និង ក្រុមគ្រួសាររបស់ពួកគេ តែងតែក្លាយខ្លួនទៅជាជនរងគ្រោះ ដោយសារតែទង្វើបែបនេះ[9] ”*

**គោលបំណងជាក់លាក់:**

៥.១ ពង្រឹងសមត្ថភាពរបស់ NOVCTF ក្នុងការដឹកនាំ ដើម្បីជា ប្រយោជន៍ដល់ OVC

៥.២ ពង្រឹងកិច្ចសំរបសំរួលរវាងស្ថាប័នពាក់ព័ន្ធ ដែលកំពុងដើរតួក្នុងការកាត់បន្ថយផលប៉ះពាល់នៃមេរោគអេដស៍ចំពោះកុមារ

៥.៣ ជំរុញឱ្យកុមារ មេដឹកនាំ និង សហគមន៍ គាំទ្រដល់ OVC

៥.៤ កសាងសមត្ថភាពរបស់ NOVCTF ក្នុងការកំនត់សំគាល់ កៀងគរ និង ផ្តល់ធនធានដែលចាំបាច់សំរាប់ការអនុវត្តន៍ផែនការនេះប្រកបដោយប្រសិទ្ធភាព

៥.៥ ផ្តល់ឱ្យអ្នកធ្វើការសំរេចចិត្ត សកម្មជន និង អ្នកគាំទ្រ នូវព័ត៌មាន ដែលចាំបាច់ក្នុងការកាត់បន្ថយផលប៉ះពាល់នៃមេរោគអេដស៍ចំពោះ OVC ប្រកបដោយប្រសិទ្ធិភាព

## បទដ្ឋានកញ្ចប់អប្បបរមានៃកិច្ចគាំទ្រ

ផ្នែកខាងក្រោមនេះនឹងផ្តល់នូវការកំណត់និយមន័យ និងខ្លឹមសារដែលបានព្រមព្រៀងគ្នារួចហើយស្តីពីបទដ្ឋានកញ្ចប់អប្បបរមានៃកិច្ចគាំទ្រដែលត្រូវផ្តល់អោយ OVC ។

---

[9] UNICEF (2004) ក្របខណ្ឌការងារសំរាប់ការការពារ ថែទាំ និង គាំទ្រ ចំពោះកុមារកំព្រា និង កុមារងាយរងគ្រោះ ដែលកំពុងរស់នៅក្នុងពិភពនៃមេរោគអេដស៍ និង ជំងឺអេដស៍, ទំព័រទី២០

កញ្ចប់អប្បបរមានៃកិច្ចគាំទ្រ រួមមានៈ

- សន្តិសុខស្បៀងអាហារ
- ការគាំទ្រផ្នែកចិត្តសង្គម
- ការគាំទ្រផ្នែកសេដ្ឋកិច្ច
- ការគាំទ្រផ្នែកអប់រំ
- ការគាំទ្រផ្នែកសុខភាព

| **បទដ្ឋានកញ្ចប់អប្បបរមានៃកិច្ចគាំទ្រ** | **ខ្លឹមសារនៃកញ្ចប់និមួយៗ** |
|---|---|
| សន្តិសុខស្បៀងអាហារ | ▪ អង្ករ ចំនួន ៣០ គីឡូក្រាម ក្នុងមួយខែ សំរាប់កុមារ OVC ១ នាក់<br>▪ ប្រេងឆា ចំនួន ១ លីត្រ ក្នុងមួយខែ<br>▪ អំបិលអ៊ីយ៉ូត ចំនួន ០.៥ គីឡូក្រាម ក្នុងមួយខែ<br>▪ ទឹកត្រី ចំនួន ១ លីត្រ ក្នុងមួយខែ |
| ការគាំទ្រដើម្បីស្តារឡើងវិញផ្នែកផ្លូវចិត្ត រឺ ចិត្តសាស្ត្រ | **ចំពោះកុមារៈ** ផ្តល់ប្រឹក្សា ចុះសួរសុខទុក្ខតាមផ្ទះ សកម្មភាពកំសាន្តផ្សេងៗ ( ការលេងកំសាន្តក្លឹបកុមារ ការប្រមូលផ្តុំក្នុងសង្គមផ្សេងៗ ។ល។) សៀវភៅកំណត់ត្រាផ្សេងៗ ។ល។<br><br>**ចំពោះអ្នកថែទាំៈ** ផ្តល់ប្រឹក្សា ចុះសួរសុខទុក្ខតាមផ្ទះ ការឈប់សំរាកពីការងារបណ្តាញអ្នកថែទាំ ។ល។<br><br>▪ **ការគាំទ្រឱ្យមានការជឿជាក់លើខ្លួនឯងៈ** ការអប់រំ/បណ្តុះបណ្តាលជំនាញ បំនិនជីវិតដល់កុមារ និងអ្នកថែទាំ ដូចជាជំនាញក្នុង ការធ្វើការសំរេចចិត្ត ការទំនាក់ទំនង ការចរចា ការដោះស្រាយបញ្ហា ការកាត់បន្ថយការតានតឹង អារម្មណ៍ ការបង្កើតមុខរបរ/ប្រាក់ចំណូលខ្នាតតូច ការគ្រប់ គ្រងគ្រួសារ ។ល។<br>▪ **ការធ្វើសមាហរណកម្ម**ចូលទៅក្នុងគ្រួសារ សាលារៀន កន្លែងការងារ<br>▪ **ជំនាញគ្រប់គ្រងករណីសំរាប់អ្នកធ្វើការងារសង្គមៈ** មនុស្សទាំងអស់ដែលមានទំនាក់ទំនងជាមួយកុមារ ត្រូវបានទទួលការបណ្តុះបណ្តាលលើការងារសង្គម ជាពិសេសការគ្រប់គ្រងករណី<br>▪ **ការទាក់ទាញការគាំទ្រ** ដើម្បីដោះស្រាយការមាក់ងាយ និងការរើសអើង |

| | |
|---|---|
| | សមភាពនៃការទទួលការអប់រំ ការចុះបញ្ជីកំណើត អាហារ និងអាហាររូបត្ថម្ភ ជំរក (ការថែទាំជំនួស) |
| ការគាំទ្រផ្នែកអប់រំ | កញ្ចប់នៃការអប់រំក្នុងប្រព័ន្ធត្រូវៈ<br>▪ លើកទឹកចិត្តអោយឪពុកម្តាយ/គ្រួសារចុះឈ្មោះកុមារចូលរៀន<br>▪ បំផុសចលនា "ការគាំទ្ររបស់សហគមន៍" ដើម្បីគាំទ្រការអប់រំសំរាប់ OVC (សៀវភៅ ប៊ិច ឯកសណ្ឋាន ការធ្វើដំណើរ ។ល។<br>▪ ធានាថាការចែកចាយសៀវភៅសំរាប់គ្រូ និងសៀវភៅសំរាប់សិស្ស និងសំភារៈសំរាប់អានមួយចំនួនទៀតបានដល់ដៃលោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និងសហគមន៍ផ្ទាល់ ជាពិសេសនៅតាមតំបន់ដាច់ស្រយាល<br>▪ ផ្តល់អាហាររូបករណ៏ដល់កុមារតាមសេចក្តីត្រូវការ ដែលអាចកាត់បន្ថយអត្រាកុមារដែលទៅតាមឪពុកម្តាយរបស់ពួកគេ (ការផ្លាស់ប្តូរទីលំនៅតាមរដូវកាល)<br>▪ បង្កើត "មជ្ឈមណ្ឌលរៀនសូត្រក្នុងសហគមន៍"ដោយរួមមានសកម្មភាពជាច្រើន ដែលជួយឱ្យកុមារចាប់អារម្មណ៏លើការរៀនសូត្រជួយកាត់បន្ថយការរៀនត្រួតថ្នាក់ ឬក៏ការឈប់រៀនព្រមទាំងអាចផ្តល់នូវជំនាញបំណិនជីវិតដល់កុមារទៀតផង<br>▪ ទាក់ទាញការគាំទ្រនៅគ្រប់ជាន់ថ្នាក់ទាំងអស់ដោយផ្តោតទៅលើរាល់បញ្ហាទាំងអស់ដែលពាក់ព័ន្ធទៅនិងការអប់រំរបស់ OVC |
| | **ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញបំណិនជីវិត សំរាប់យុវជនក្រៅសាលាៈ**<br><br>ជំនាញបំណិនជីវិតរួមមានការយល់ដឹងដោយខ្លួនឯង ការទំនាក់ទំនង ជំនាញទំនាក់ទំនងអន្តរបុគ្គល គំនិតច្នៃប្រឌិត ការសំរេចចិត្ត ការដោះស្រាយបញ្ហា ចំណេះដឹងអំពីមេរោគអេដស៏ និងការអប់រំដៃគូ |
| ការគាំទ្រផ្នែកសេដ្ឋកិច្ច | ▪ គាំទ្រកុមារធំៗ និង/រឺសមាជិកពេញវ័យនៅក្នុងគ្រួសារ OVC ឬក៏គ្រួសារ ទទួលផលប៉ះពាល់ដោយមេរោគអេដស៏ឱ្យទទួលបានការបណ្តុះបណ្តាល វិជ្ជាជីវៈ/ ជំនាញ<br>▪ ធានាថាគ្រួសារ OVC រឺក៏គ្រួសារទទួលផលប៉ះពាល់ដោយមេរោគអេដស៏ ទទួលបានកម្មវិធីឥណទានខ្នាតតូចដោយមិនគិតការប្រាក់<br>▪ ផ្តល់កម្មវិធីធនាគារសត្វពាហនៈ ដូចជាគោក្របី/ពពែ/ជ្រូក |

| | |
|---|---|
| | ▪ បង្កើនលទ្ធភាពគ្រួសារក្នុងការផលិតអាហារហូបចុកគ្រប់គ្រាន់ ឬក៏សំរាប់លក់ដូរផងដែរ រាប់បញ្ចូលទាំងការដាំបន្លែបង្ការ ដំណាំស្រូវ ការចិញ្ចឹមសត្វពាហនះ/មាន់ទា /ត្រី និងផលិតផលសិប្បកម្មផ្សេងៗទៀត<br>▪ បណ្តុះបណ្តាលគ្រួសារនូវជំនាញបំណិនជីវិតដែលពាក់ព័ន្ធទៅនិងសកម្មភាព បង្កើនប្រាក់ចំណូល រាប់បញ្ចូលយ៉ាងហោចណាស់ក៏ ជំនាញគ្រប់គ្រងហិរញ្ញវត្ថុជាមូលដ្ឋាន ជំនាញគ្រប់គ្រងមុខជំនួញខ្នាតតូច និងជំនាញផ្នែកគិតលេខ និងសរសេរអក្សរ<br>▪ ធ្វើការតាមដានគ្រួសារយ៉ាងទៀងទាត់ដើម្បីត្រួត ពិនិត្យ និងផ្តល់ការ គាំទ្រ ផ្នែកបច្ចេកទេស រហូតគ្រួសារនោះមានភាពរឹងមាំគ្រប់គ្រប់អាចក្រោកឈរដោយខ្លួនឯងបាន ។ |
| ការគាំទ្រផ្នែកសុខភាព | ការទទួលបាននូវសេវាសុខភាពសមស្រប:<br>- ចំពោះ OVC ដែលមានអាយុចាប់ពី 0 ដល់ ៥ឆ្នាំ សេវាសុខភាព រួម មានការចាក់ថ្នាំបង្ការគ្រប់ ចំនួន ការផ្តល់ថ្នាំវីតាមីនបន្ថែម ការពិនិត្យសុខភាពជាប្រចាំ និង សេវាធ្វើតេស្តឈាម រកមេរោគអេដស៍<br>- ចំពោះ OVC ដែលមានអាយុចាប់ពី ៦ ដល់ ១៣ឆ្នាំ សេវាសុខភាពរួមមានការផ្តល់ថ្នាំវីតាមីន បន្ថែម ការពិនិត្យសុខភាពជាប្រចាំ ការធ្វើតេស្តឈាមរកមេរោគអេដស៍ ការថែទាំ សុខភាពបន្តពូជនិងសេវាផ្តល់ពិតមានអំពីការបង្ការមេរោគអេដស៍<br>- ចំពោះ OVC ដែលមានអាយុចាប់ពី ១៤ ដល់ ១៨ឆ្នាំ សេវាសុខភាពរួមមានការថែទាំសុខភាព ជាប្រចាំសំរាប់ OVC និងអ្នកថែទាំ ការថែទាំសុខភាពបន្តពូជសេវាផ្តល់ពិតមានអំពីការបង្ការមេរោគ អេដស៍ និងសេវាធ្វើ តេស្តឈាមរកមេរោគអេដស៍ |
| **កញ្ចប់ផ្សេងៗនៃកិច្ចគាំទ្រ** | |
| កញ្ចប់អប្បបរមានៃកិច្ចគាំទ្រផ្នែកសង្គមសំរាប់កុមារដែលកំពុងទទួលការព្យាបាលមេរោគអេដស៍( ការព្យាបាលដោយប្រើថ្នាំ ARVឬក៏ការព្យាបាលឬបង្ការជំងឺឱកាសនិយមផ្សេងៗ) | ▪ ជំនួយស្បៀងអាហារ<br>▪ ការធ្វើដំណើរ<br>▪ ការអមដំណើរដែលផ្តល់ទំនុកចិត្ត<br>▪ ការគាំទ្រជាប់លាប់ |

**ឧបសម្ព័ន្ធទី១**

តារាងសមាជិកគណកម្មការនាយក ដែលរួមមាន ឈ្មោះ និង ទីកន្លែងធ្វើការរបស់អ្នកចូលរួម សំរាប់ក្រុមការងារនិមួយៗ សិក្ខាសាលាខេត្ត និង សិក្ខាសាលាជាតិ (ទំនាក់ទំនងទទួលពតិមាន ពី លោក វ៉ាន់ឌី ឬក៏អ្នកផ្សេងដែលនៅក្នុងក្រុមការងារលេខាធិការដ្ឋាន)

## សិក្ខាសាលាក្រុងព្រះសីហនុ

## បញ្ជីវត្តមានអ្នកចូលរួម, សិក្ខាសាលា អំពីផែនការសកម្មភាពជាតិ ៦-៧ មិថុនា ២០០៧ នៅ សណ្ឋាគារខ្សាច់មាស

| No. | Name | Sex | Title/Position | Institution |
|---|---|---|---|---|
| 1 | H.EKhoy Sokha | M | Dep Governor | Svay Rieng |
| 2 | Morm Maly | F | Chief of Administration | Information |
| 3 | Ain Manith | F | Court | Court of Sihanoukville |
| 4 | Som Soporn | M | Staff | CCPCR |
| 5 | Mony Sisovan | M | Director | CCPOAR |
| 6 | Mok Sareoun | M | Deputy Director | Education |
| 7 | Korng Dyna | M | Deputy Director | PoCR |
| 8 | Ke Hukdom | M | Deputy Director | PoLVT |
| 9 | Serju Sithjut | M | Deputy Director | PHD |
| 10 | Nuy Pengjev | M | Deputy Director | PoRD |
| 11 | Seng Kuteara | M | Staff | AFFESIP |
| 12 | Pov Vanny | F | Chief Of Gender | PMoWA |
| 13 | Mak Sros | F | Staff | PSAVY/ M'LOPTAPANG |
| 14 | Bou Somart | M | | CPCDO, PNH |
| 15 | Khat Sovan | M | Staff | PC TAKEO |
| 16 | Pol  Sarorn | M | Translator | PNH |
| 17 | Jeanne Roberts | F | Consultant | OVC Task Force |
| 18 | Kien Seryphal | F | Consultant | OVC Task Force |
| 19 | Sok Kheng | F | Staff | VCAO, PNH |
| 20 | Sok Phanna | F | Programme Officer | KT PNH |
| 21 | Keo Sarim | M | Staff | CWPD,KSPE |
| 22 | Py Sarart | F | Staff | SIT KD |
| 23 | Em Sovanny | F | Programme Officer | ASPECA KP |
| 24 | Nam Phanat | M | Programme Officer | KC.DI KP |
| 25 | Ho Map | F | | Kep organization |
